**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៤

# ញត្តិសហគមន៍

យើងខ្ញុំទាំងអស់គ្នាជាតំណាងសហគមន៍ជនជាតិដើមភាគតិចពូនង ចារាយ គ្រឹង ព្រៅ ឡាវ និងខ្មែរ ដែលរស់នៅតាម ដងទន្លេសេសាន និងទន្លេស្រែពកមកពីភូមិក្នុងតំបន់គម្រោងគទំនប់វារីអគ្គិសនីសេសានក្រោម២ ដូចជា ភូមិក្បាល រមាស ភូមិស្រែគរ១ និងស្រែគរ២ ភូមិច្រប់ ក្របីជ្រុំ ភូមិភ្លុក និងខ្សាច់ថ្មី ក្នុងស្រុកសេសាន ខេត្ត ស្ទឹងត្រែង មានការព្រួយបារម្ភអំពីផលប៉ះពាល់ពីគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលមានកំលាំង៤០០មេហ្គាវ៉ាត់។

## សូមគោរពជូន

## សម្តេចអគ្គមហាពញាចក្រ ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

កន្លងមមកយើងខ្ញុំធ្លាប់បានដាក់សេចក្តីថ្លែងការណ៍ជូនគណៈកម្មការដោះស្រាយផលប៉ះពាល់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២នៅខេត្តស្ទឹងត្រែង ជូនមន្ទីរនិងក្រសួងពាក់ព័ន្ធ ព្រមទាំងស្ថានទូតចិនប្រចាំនៅប្រទេសកម្ពុជា និងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាដែរ ប៉ុន្តែយើងខ្ញុំមិនដែលទទួលបាននូវការឆ្លើយតប ទាល់តែសោះ ដូច្នេះហើយទើបយើងខ្ញុំយកឱកាសថ្ងៃនេះ នាំយកនូវញត្តិរបស់យើងខ្ញុំដាក់ជូនរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំជាតំណាងសហគមន៍រងគ្រោះ **សូមធ្វើការស្នើរសុំយ៉ាងទទូច និងដោយក្តីអង្វរដល់សម្តេចអគ្គមហាពញាចក្រ ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា សូមជួយអន្តរាគមន៍ លុបចោលគម្រោងទំនប់វារីអគ្គសនីសេសានក្រោម២ជាបន្ទាន់**

យើងខ្ញុំសូមបញ្ជាក់នូវចំនុចដែលសំខាន់ គឺយើងខ្ញុំសុំធ្វើការបដិសេធមិនចាកចេញពីភូមិរបស់យើងខ្ញុំទេ និងស្នើរសុំឱ្យលុបចោលនូវគម្រោងនេះ ដោយសារតែ ៖

- យើងខ្ញុំមានភាពសប្បាយរីករាយនឹងរស់នៅក្នុងភូមិរបស់យើង ជាមួយនឹងភាពសម្បូរណ៍ហូរហៀរនៃធនធានធម្មជាតិដែលនៅជុំវិញខ្លួនយើងនាពេលសព្វថ្ងៃនេះណាស់។ ធនធានធម្មជាតិទាំងនេះបានជួយទ្រទ្រង់ដល់ការរស់នៅប្រចាំថ្ងៃរបស់យើង ហើយជាងនេះទៅទៀត តាមវប្បធម៌ ឬទំនៀម

ទំលាប់របស់ពួកយើង គឺមានមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅទៅនឹងដីធ្លីរបស់បុព្វបុរស ដែលបានបន្សល់ទុកឲ្យយើងជាកូន និងជាចៅក្នុងជំនាន់ និងជំនាន់ក្រោយៗទៀត

- យើងមានដីភូមិដ៏ស្រស់ស្អាត និងជាទីស្រលាញ់ ដែលសម្បូរទៅដោយធនធានធម្មជាតិសម្រាប់ទ្រទ្រង់ជីវិតរបស់យើងដូចជា ចំណីអាហារ និងប្រភពប្រាក់ចំណូលជាដើម។ ធនធានទាំងនេះមានដូចជាដីភូមិ ដីកសិកម្ម ដីបំរុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ព្រៃសំរាប់ចិញ្ចឹមសត្វ ដីកប់ខ្មោចនិងផ្នូរដូនតា ព្រៃតំណម ព្រៃសក្ការៈបូជា ទន្លេ និងធនធានទាំងឡាយជាច្រើនទៀតដែលមាននៅក្នុងទឹក និងលើគោកផងដែរ ហើយអ្វីដែលសំខាន់ គឺធនធានធម្មជាតិទាំងនេះ មិនអាចកាត់ថ្លៃបានទេ

- ជាពិសេសទន្លេ គឺសំខាន់ខ្លាំងណាស់សម្រាប់យើងខ្ញុំ។ យើងខ្ញុំទាំងអស់គ្នាមានជីវិតរស់នៅជាប្រជានេសាទ។ យើងខ្ញុំអាចរកប្រាក់ចំណូលពីការលក់ត្រីដែលនេសាទបាន ហើយយើងខ្ញុំបរិភោគត្រីជារៀងរាល់ថ្ងៃផងដែរ។ ប្រសិនបើបាត់បង់ទន្លេនោះយើងខ្ញុំនឹងមុខជាពិបាកក្នុងការរកទទួលទានដើម្បីរស់រានមានជីវិតខ្លាំងណាស់

- ធនធានធម្មជាតិទាំងអស់នេះ ក៏មានទំនាក់ទំនងគ្នាយ៉ាងជិតស្និតទៅនឹងវប្បធម៌ និងទំនៀមទំលាប់ប្រពៃណីក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងដែលមិនអាចខ្វះបាន។ យើងខ្ញុំមានជំនឿលើអារក្សអ្នកតាដែលបានរស់នៅជាមួយព្រៃឈើ ភ្នំ និងគ្រប់ទីកន្លែងក្នុងភូមិរបស់យើង។ អារក្សអ្នកតាបាននាំមកឲ្យយើងនូវសេចក្តីសុខសប្បាយ ជួយថែរក្សាការពារដីធ្លីរបស់យើង ជួយដោះស្រាយបញ្ហា និងជួយកសាងសាមគ្គីភាពក្នុងសហគមន៍ឲ្យរឹងមាំតាមរយៈពិធីបុណ្យអារក្សអ្នកតាផ្សេងៗ។ ជាឧទាហរណ៍៖ យើងខ្ញុំធ្លាប់ប្រារព្ធពិធីបន់ស្រន់ដល់អ្នកតាក្រហម ក ជារៀងរាល់ឆ្នាំនៅរោងអ្នកតាក្រហម ក ដែលមានទីតាំងបិតនៅមាត់ទន្លេសេសាន ដើម្បីសុំក្តីសុខសប្បាយកើតមានដល់សហមន៍យើងខ្ញុំ និងសុំអ្នកតាមកជួយថែរក្សាការពារបរិស្ថាន ឬធនធានធម្មជាតិ ពិសេស គឺថែរក្សាទន្លេរបស់យើងឲ្យគង់វង្ស និងមានលំហូរធម្មជាតិជានិច្ច។ អ្នកតាក្រហម ក គឺមានសារៈសំខាន់ដើម្បីភ្ជាប់ការគោរពបូជាទៅដល់បុព្វបុរសរបស់យើង ប្រសិនបើយើងបាត់នូវទីកន្លែងជាទីសក្ការៈដូចជាអ្នកតាក្រហម ក ដោយសារតែគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ យើងក៏នឹងបាត់បង់នូវវប្បធម៌ និងទំនៀមទំលាប់ប្រពៃណីរបស់យើងដូច្នោះដែរ។ នៅពេលដែលយើងបាត់បង់នូវធនធានធម្មជាតិទាំងនេះ និងវប្បធម៌ ព្រមទាំងទំនៀមទំលាប់ប្រពៃណីហើយនោះ គឺពិតជាមិនអាចបង្កើតឡើងវិញបានទេ។

- វប្បធម៌ ទំនៀមទំលាប់ប្រពៃណី ព្រៃអារក្ស អ្នកតា ព្រៃកប់ខ្មោច ព្រៃតំណម ផ្នូរដូនតា ជីវចំរុះទន្លេដែលជាកេរ្តិ៍មរតកពីដូនតា និងជាប្រភពរកចំណីអាហារ និងប្រាក់ចំណូលរបស់យើងគឺមិនអាច

ទូទាត់សងជាប្រាក់ ឬរើទៅកន្លែងណាផ្សេងបាននោះទេ។ ប្រសិនបើយើងចាកចេញពីភូមិ នោះយើងខ្ញុំនឹងបាត់បង់នូវអត្តសញ្ញាណរបស់យើងជាក់ជាមិនខាន

- យើងខ្ញុំធ្លាប់បានឮពីអាជ្ញាធរមូលដ្ឋានក្នុងតំបន់បាននិយាយថា ភូមិខ្សាច់ថ្មី និងភូមិក្របីជ្រុំ នឹងមិនត្រូវលិចទឹកដោយសារតែអាងស្តុកទឹករបស់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២នោះទេ ប៉ុន្តែភូមិយើងខ្ញុំត្រូវបានទឹកជំនន់ជន់លិចជារៀងរាល់ឆ្នាំទៅហើយ ដែលធ្វើឲ្យយើងខ្ញុំរត់គេចទៅនៅតំបន់ខ្ពស់នៅពេលជន់លិចម្តងៗ។ ដូច្នេះ បើទំនប់សេសានក្រោម២ត្រូវបានសាងសង់ក្បែរភូមិរបស់យើងខ្ញុំទៀតនោះ យើងខ្ញុំជឿជាក់ថា ភូមិយើងខ្ញុំគឺច្បាស់ជាត្រូវលិចទឹកជាក់ជាមិនខាន ហើយយើងខ្ញុំក៏មិនអាចរស់នៅក្នុងភូមិនេះបន្តទៀតដែរ

- យោងតាមគោលការណ៍ណែនាំរបស់ប្រទេសចិនសម្រាប់ការការពារបរិស្ថានក្នុងការវិនិយោគបរទេសក្នុង កិច្ចសហប្រតិបត្តិការនោះ បានបង្ហាញថា មិនគួរអនុវត្តនូវរាល់សកម្មភាពណាមួយ ឬការអភិវឌ្ឍណាមួយដែលធ្វើឲ្យមានការប៉ះពាល់ដល់អត្តសញ្ញាណ ឬកន្លែងអារក្ស ទីសក្ការៈបូជារបស់ជនជាតិដើមភាគតិចនោះទេ។ គោលការណ៍ណែនាំនេះ គឺសំខាន់ណាស់ក្នុងការចូលរួមថែរក្សានូវបរិស្ថាន និងទំនៀមទំលាប់របស់យើងទាំងអស់គ្នាក្នុងប្រទេសកម្ពុជា តែយ៉ាងណាមិញ ក្រុមហ៊ុនទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលមានការចូលភាគហ៊ុនគ្នារវាងក្រុមហ៊ុនហាយដ្រូឡានឆាងរបស់ចិន (China's Hydrolancang International Energy) និងរ៉ូយ៉ាល់គ្រុប គឺមិនបានអនុវត្តតាមគោលការណ៍ណែនាំនេះនោះទេ។ សូមសម្តេចប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មេត្តាពិចារណានូវបញ្ហានេះ និងជម្រុញឲ្យពួកគេគោរពតាមគោលការណ៍ណែនាំនេះផង

- ទំនប់វារីអគ្គិសនីសេសានក្រោម២នេះ នឹងកាត់ផ្តាច់លំហូរទឹកទន្លេសេសាន និងទន្លេស្រែពកទៅក្នុងទន្លេ មេគង្គ។ មានត្រីជាច្រើនប្រភេទដែលចរាចរណ៍ឡើងតាមទន្លេសេសាន និងទន្លេស្រែពក ដើម្បីពងកូន ដូច្នេះ បើទំនប់វារីអគ្គិសនីសេសានក្រោម២កាត់ផ្តាច់ចរាចរណ៍ត្រី នោះនឹងបង្កឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ធនធានជលផលទាំងផ្នែកខាងលើ និងខាងក្រោម រួមទាំងអាងបឹងទន្លេសាប និងទន្លេមេគង្គទាំងមូល។ ត្រី គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនទាំងអស់ក្នុងប្រទេសកម្ពុជាទាំងមូល គឺមិនមែនតែសម្រាប់ប្រជាជនដែលរស់នៅតាមដងទន្លេប៉ុណ្ណោះទេ។ ប្រជាជនរាប់លាននាក់ គឺបរិភោគត្រី និងរកប្រាក់ចំណូលពីសកម្មភាពនេសាទត្រីជារៀងរាល់ថ្ងៃ។ យើងអាចនិយាយបានថា ត្រីគឺជាទ្រព្យសម្បត្តិរបស់ប្រទេសកម្ពុជា។ បើសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ប្រទេសកម្ពុជា មានន័យថាគម្រោងនេះ គឺមិនមែនជាគម្រោងអភិវឌ្ឍដ៏ល្អមួយនោះទេ។

- យើងគិតថា "**ការអភិវឌ្ឍន៍**" គឺគួរតែធ្វើឲ្យប្រជាជនកម្ពុជាដូចជាយើងខ្ញុំបានសប្បាយរីករាយជាងមុន។ អាជ្ញាធរ ដូចជារូបលោក ដែលមានអំណាច និងមានការអប់រំ ចំណេះដឹងខ្ពង់ខ្ពស់ជាងសហគមន៍យើងខ្ញុំគួរតែស្វែងរកនូវដំណោះស្រាយដ៏ល្អសម្រាប់ដោះស្រាយនូវបញ្ហានេះ ប្រសើរជាងធ្វើឲ្យសហគមន៍យើងខ្ញុំរងទុក្ខវេទនា។ ចុះប្រសិនបើទំនប់វារីអគ្គិសនីសេសានក្រោម២នេះត្រូវបានសាងសង់ក្បែរផ្ទះវិឡា ផ្ទះដូនតារបស់អស់លោកវិញ តើអស់លោកនឹងមានការឈឺចាប់ដែរឬទេ?

**យើងខ្ញុំសំណូមពរដល់សម្តេចប្រធានរដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម៖**

- **សូមរដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជាមេត្តាទទួលយកនូវក្តីកង្វល់របស់យើងខ្ញុំ និងរាល់ផលប៉ះពាល់ដែលបង្ករឡើងដោយសារគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២មកលើប្រទេសកម្ពុជាមកពិនិត្យ ពិចារណា និងជួយអន្តរាគមន៍ដល់រដ្ឋាភិបាលកម្ពុជា និងអ្នកអភិវឌ្ឍន៍នានា លុបចោលនូវគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២នេះជាបន្ទាន់**

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា រាល់ក្តីបារម្ភ និង សំណូមពរទាំងអស់ដែលបានលើកឡើងខាងលើនឹងត្រូវបានយកចិត្តទុកដាក់ និងដោះស្រាយជូនយើងខ្ញុំជាក់ជាមិនខាន។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមក៖

1. លោក ដាំ សំណាង តំណាងសហគមន៍ភូមិក្បាលរមាស ខេត្តស្ទឹងត្រែង ៖ ០៨៨ ៥ ៨៤០ ៧៦២
2. លោកស្រី សារុន ខុំតំណាងសហគមន៍ភូមិស្រែគរ២ ខេត្តស្ទឹងត្រែង ៖ ០៩៧៥៧០៣៧៣៥
3. លោក ស្រី លី បិ តំណាងសហគមន៍ភូមិច្រប់ ខេត្តស្ទឹងត្រែង ៖ ០៩៧ ៥ ០០១ ៨០៦
4. លោក សូភី វាសនា តំណាងសហគមន៍ភូមិក្របីជ្រុំ ខេត្តស្ទឹងត្រេង ៖ ០៨៨៧០៥៣៥៨៥
5. លោក សាយ ស៊ីម តំណាងសហគមន៍ភូមិខ្សាច់ថ្មី ខេត្តស្ទឹងត្រែង ៖ ០៨៨៩៤០៩៨៣៦
6. លោក សៃ ដួងពិសិដ្ឋតំណាងសហគមន៍ភូមិភ្លុក ខេត្តស្ទឹងត្រែង ៖ ០៩៧ ២៨៤៥ ៧១៨
7. លោកស្រី ពីង ចំរើនតំណាងសហគមន៍ភូមិតាវែង ខេត្តរតនគិរី ៖ ០៩៧ ៦៥០១ ២៤៧
8. លោក តន់ ជាងតំណាងសហគមន៍ភូមិលំផាត់ ខេត្តរតនគិរី ៖ ០៨៨ ៣០០២ ៦៧០
9. លោក ម៉ុក ស្រេងតំណាងសហគមន៍ភូមិកូនមុំ ខេត្តរតនគិរី ៖ ០៩៧ ៩២២៧ ៩៣៧
10. លោកស្រី ហ្វយ ស៊ុតតំណាងសហគមន៍ភូមិវើនសៃ ខេត្តរតនគិរី ៖ ០៨៨ ៧០៦៩ ៥៣១

*<u>ចម្លងជូន</u>*

- *ក្រសួងរ៉ែ និងថាមពល*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

- *ក្រសួងបរិស្ថាន*
- *ក្រសួងអភិវឌ្ឍន៍ជនបទ*
- *ក្រសួងធនធានទឹក និងឧត្តុនិយម*
- *ស្ថានទូតចិនប្រចាំនៅកម្ពុជា*
- *ក្រុមហ៊ុនទំនប់សេសានក្រោម២ និងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប*
- *ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា*
- *គណៈកម្មាធិការជាតិទន្លេមេគង្គវៀតណាម*
- *គណៈកម្មាធិការជាតិទន្លេមេគង្គឡាវ*
- *គណៈកម្មាធិការជាតិទន្លេមេគង្គថៃ*
- *សាព័ត៌មាន និងអង្គការសង្គមស៊ីវិល ក្នុងប្រទេសទន្លេមេគង្គ និងអន្តរជាតិ*